ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស
លេខ: ០០៥/១៦ ស.ព.ក.ព.ម

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃសុក្រ ទី ២៧ ខែ ឧសភា ឆ្នាំ ២០១៦

នៅព្រឹកថ្ងៃសុក្រទី២៧ ខែឧសភា ឆ្នាំ ២០១៦ វេលាម៉ោង៨ និង៣០នាទី នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លង៖

**១- សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស។**

**២- បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ៖**

**២.១- ពិធីសារវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។**

**២.២- កិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋាភិបាលនៃរដ្ឋសមាជិក សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន រួមទាំងពិធីសារចំនួន២។**

**២.៣- ពិធីសារអនុវត្តកញ្ចប់សន្យាទី៧ និងទី៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម។**

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត៖

## ១- សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស

អនុលោមតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោក ជំងឺមិនឆ្លងមានដូចជាជំងឺលើសឈាម ជំងឺទឹកនោមផ្អែម កំពុងតែរាតត្បាតទៅគ្រប់ប្រទេសលើសកលលោកជាពិសេសក្នុងប្រទេសដែលមានសេដ្ឋកិច្ចមធ្យម ឬខ្ពស់។ ជំងឺមិនឆ្លងទាំងនេះភាគច្រើនទាមទារអោយមានការថែទាំយូរអង្វែង ហើយការវិវត្តចុងក្រោយរបស់ជំងឺនេះ វាអាចនឹងធ្វើអោយអ្នកជំងឺស្លាប់ដោយសារការខូចខាតសរីរាង្គណាមួយ។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការព្យាបាលជំងឺមិនឆ្លងទាំងនេះ វិស័យ

ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៤១ មហាវិថីសហព័ន្ធរុស្ស៊ី
ទូរសារលេខ: ០២៣ ២១២ ៤៩០, ទូរស័ព្ទ: ០១២ ៨៤៨
អ៊ីមែល: pressocm@gmail.com

វេជ្ជសាស្ត្របានធ្វើការសិក្សាស្រាវជ្រាវ និងទទួលបានជោគជ័យយ៉ាងធំក្នុងការសង្គ្រោះជីវិតអ្នកជំងឺដោយសារការយកសរីរាង្គពីមនុស្សម្នាក់ទៅផ្សាំនៅក្នុងខ្លួនរបស់អ្នកជំងឺដែលមានសរីរាង្គខូចមិនដំណើរការ សរីរាង្គមនុស្សដែលគេអាចផ្សាំបាន ហើយត្រូវបានអនុវត្តញឹកញាប់ជាងគេគឺតម្រងនោម (ក្រលៀន)។

ដោយការអភិវឌ្ឍលើវិស័យវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រក្នុងប៉ុន្មានទស្សវត្សន៍ចុងក្រោយនេះ ការផ្សាំតម្រងនោម(ក្រលៀន) ក្លាយជាជម្រើសផែនការព្យាបាលដ៏មានប្រសិទ្ធភាព និងពេញនិយមនៅតាមប្រទេសជឿនលឿន នៅលើពិភពលោកសម្រាប់អ្នកជំងឺខូចតម្រងនោម (ក្រលៀន) ដែលទាមទារអោយមានការលាងឈាមជាប្រចាំ។ ចំនួនអ្នកជំងឺដែលខូចតម្រងនោម (ក្រលៀន) ដែលរង់ចាំផ្សាំតម្រងនោម (ក្រលៀន) បានកើនឡើងយ៉ាងលឿនពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារកង្វះការបរិច្ចាគតម្រងនោម (ក្រលៀន)។

អតុល្យភាពរវាងតម្រូវការតម្រងនោម (ក្រលៀន) និងការបរិច្ចាគតម្រងនោម (ក្រលៀន) បានជំរុញអោយមាននិន្នាការនៃការជួញដូរតម្រងនោម (ក្រលៀន) នៅក្នុងប្រទេស និងឆ្លងដែន។ ការជួញដូរសរីរាង្គត្រូវបានប្រទេសទាំងអស់ផ្តោលទោសតាមរយៈការរៀបរៀងច្បាប់សម្រាប់ការគ្រប់គ្រងការបរិច្ចាគ និងការផ្សាំសរីរាង្គសម្រាប់ប្រទេសរបស់គេរៀងៗខ្លួន។

សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងលើការបរិច្ចាគការផ្សាំកោសិកា ជាលិកានិងសរីរាង្គមនុស្សត្រូវបានរៀបចំឡើងដោយក្រសួងសុខាភិបាល ក្នុងគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងតម្លាភាពក្នុងការព្យាបាលសង្គ្រោះជីវិត និងបង្កើនសុខុមាលភាពរបស់ប្រជាពលរដ្ឋតាមរយៈការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស និងធានាការពារទប់ស្កាត់ការជួញដូរកោសិកា ជាលិកា ឬសរីរាង្គមនុស្ស។

សេចក្តីព្រាងច្បាប់នេះ មាន៦ ជំពូក និង៣៤មាត្រា មានគោលដៅកំណត់អំពីវិធាន និងនីតិវិធីក្នុងការគ្រប់គ្រង ការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្សប្រកបដោយសុវត្ថិភាព និងស្របតាមក្រមសីលធម៌វិជ្ជាជីវៈ។

វិសាលភាពនៃសេចក្តីព្រាងច្បាប់នេះ អនុវត្តគ្របដណ្តប់ទៅលើសកម្មភាពដែលពាក់ព័ន្ធនឹងការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស។

**២- បញ្ហាផ្សេងៗ** ៖ អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានអនុម័តបញ្ជូនទៅសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិ៖

២.១- ពិធីសារវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។

២.២- កិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋាភិបាលនៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន រួមទាំងពិធីសារចំនួន ២។

២.៣-ពិធីសារអនុវត្តកញ្ចប់សន្យាទី៧ និងទី៨ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការណែនាំដល់គ្រប់ស្ថាប័នពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់៖

១- បញ្ចប់យុទ្ធនាការចែកចាយទឹក នៅគ្រប់តំបន់ណាដែលមានភ្លៀងធ្លាក់និងមានទឹក ចំណែកតំបន់ណាដែលមិនមានទឹកគ្រប់គ្រាន់ត្រូវបន្តយកចិត្តទុកដាក់ដោះស្រាយ

២- បន្តសកម្មភាពស្តារ និងជីកស្រះ អណ្តូងទឹក ដើម្បីបង្ការការខ្វះទឹកនៅឆ្នាំក្រោយៗទៀត នៅគ្រប់តំបន់ដែលប្រឈមការខ្វះខាតទឹកនិង

៣- ត្រូវបន្តយកចិត្តទុកដាក់ត្រៀមបង្ការចំពោះគ្រោះធម្មជាតិដែលនឹងអាចកើតឡើងជាយថាហេតុ ដូចជា ខ្យល់កន្ត្រាក់ ខ្យល់ព្យុះ ទឹកជំនន់ជាដើម។

សម្តេចអគ្គមហាសេនាបតីតេជោ ក៏បានក្រើនរំលឹកបន្ថែមអំពីការបន្តចែកអាវភ្លៀងអោយបានដល់ដៃកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ជាពិសេសកងកម្លាំងដែលកំពុងឈរជើង នៅតាមខ្សែបន្ទាត់ព្រំដែន និងដែនសមុទ្រ អោយបានគ្រប់គ្រាន់ និងទាន់ពេលវេលា ក្នុងពេលដែលរដូវភ្លៀងបានចាប់ផ្តើមមកដល់។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង០៩ និង ៤៥ នាទី។

រាជធានីភ្នំពេញ, ថ្ងៃសុក្រ ទី២៧ ខែឧសភា ឆ្នាំ២០១៦